# ស្ថាននាមបុរាណដ្ឋានពីរដែលមានពាក្យ “រលំ”

*រលំ* គឺជាពាក្យមួយក្នុងភាសាខ្មែរដែលយើងតែងដឹងមានន័យថា *“ដួល ដេកទាំងស្រុង ទាំងដំហរ ឧទាហរណ៍ ដើមឈើរលំ សសររលំ”*។[១] ពាក្យនេះមានប្រើប្រាស់តាំងពីសម័យបុរាណមកម្ល៉េះ ប៉ុន្តែគេសរសេរដោយប្រើ “របាទ” ដាក់នៅលើអក្សរ “ល” និងអាចមានន័យផ្សេងមួយទៀត ដែលគេជួបនៅក្នុងសិលាចារឹកបុរាណខ្មែរយ៉ាងតិច ៩ ដូចជា ប្រាសាទអ្នកបួស ខេត្តព្រះវិហារ K.341[២] (ចន្ទ្វរ លំ៌ ស្រេ វ្នរ), សិលាចារឹកប្រាសាទព្រះក្សេត្រ ខេត្តឧត្តរមានជ័យ K.237[៣] (ភូមិ លំ៌ ស្តុត), សិលាចារឹកប្រាសាទអ្នកបួស ខេត្តព្រះវិហារ K.343[៤] (លំ៌ ហ្នះ ទិក), K.720 (លំ៌ អង្កាញ), K.229 (លំ៌ ថ្បល អំវិល), K.190 (លំ៌ ផ្ទិក), K.158 (លំ៌បញ្ចួល), K.467 (លំ៌ ទំនប្បបាក), K.257 (លំ៌ ទ្យន)។ លោក ឡុង សៀម ពន្យល់ថា “រលំ” (លំ៌) មានន័យថា “ដីបាក់ ឬច្រាំងបាក់”[៥] រីឯលោក កំ វណ្ណាវ៉ា យល់ថា “រលំ” មានន័យថា “ទំនប់ទឹក ឬទំនប់ដែលគេដាក់បាំងទឹក”។[៦] ពាក្យ “រលំ” ខ្មែរយើងបច្ចុប្បន្ន បានយកមកប្រើប្រាស់ហៅសម្គាល់ឈ្មោះស្ថាននាមជាច្រើន ហើយក្នុងនោះយើងនឹងលើកយកស្ថាននាមបុរាណដ្ឋានចំនួនពីរមកសិក្សា ពោល គឺ ប្រាសាទរលំ នៅតំបន់កោះកេរខេត្តព្រះវិហារ និងរលំស្រើស នៅខេត្តកំពង់ធំ។ តើហេតុដូចម្តេចបានគេហៅបុរាណដ្ឋានទាំងពីរនេះថាដូច្នេះ?

រលំស្រើស គឺជាឈ្មោះដែលអ្នកស្រុកហៅសំដៅលើព្រែកជីកបុរាណមួយ មានប្រវែងជាង ១០០ម៉ែត្រ ដែលមនុស្សបុរាណជីកបំបែកយកទឹកចេញពីស្ទឹងស្ទោង ត្រង់ចំណុចភូមិត្រពាំងព្រីង ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។ ព្រែកជីកបុរាណនេះ មានទទឹងប្រមាណ ១៥ ម៉ែត្រ និងមានទំនប់ដីសងខាងប្រវែងប្រមាណ ១០ម៉ែត្រ។ នៅមិនឆ្ងាយពីព្រែកជីកបុរាណនេះ សម្បូណ៌ដោយគ្រឹះប្រាសាទចាស់ៗជាច្រើន ដូចជា ប្រាសាទគ្រឹះប្រាង្គ ប្រាសាទវត្តត្រពាំងព្រីង ប្រាសាទតាប្រាំង ប្រាសាទបង្កង់ តែជាអកុសលប្រាសាទទាំងអម្បាលម៉ានបានបាក់បែកបាត់រូបរាងស្ទើរទាំងស្រុងទៅហើយ។ ប្រភពព័ត៌មានពីអ្នកស្រុកប្រាប់មកយើងថា ពួកគាត់ក៏មិនដឹង

---

[១] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ១០១២។

[២] Coedès 1954: 23; Aymonier 1901: 237.

[៣] Coedès 1954: 293; Aymonier 1901: 360.

[៤] Coedès 1954: 156; Aymonier 1901: 387.

[៥] ឡុង សៀម ១៩៩៧: ៥៣។

[៦] កំ វណ្ណាវ៉ា ២០២០: ១៧។

ច្បាស់ថា ហេតុអ្វីចាស់បុរាណហៅឈ្មោះព្រៃកដីកនេះថា "រលំស្រីស" ដូច្នេះទេ ពោល គឺពួកគាត់បានឮតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ ហើយក៏មិនដឹងថាពាក្យ "រលំ" ដែលគេហៅនេះមានន័យថាដូចម្ដេចឡើយ។ ប៉ុន្តែ អ្នកស្រុកស្ទើរគ្រប់គ្នាចងចាំរឿងព្រេងមួយដែលនិទានថា "កាលពីព្រេងនាយ មានគ្រួសារមួយប្រកបរបរជាអ្នកតម្បាញ ហើយក្នុងគ្រួសារនោះមានកូនពីរនាក់ (ស្រីម្នាក់ ប្រុសម្នាក់)។ កូនស្រីរបស់គាត់មានសម្រស់ស្អាតលើសនារីទាំងពួងនៅក្នុងភូមិ ហើយបុរសៗដែលនៅភូមិឆ្ងាយៗនិងភូមិជាមួយគ្នា តែងតែចូលស្ដីដណ្ដឹងនាងឥតស្រាកស្រាន្ត ប៉ុន្តែនាងក្រមុំមិនព្រមយកឡើយ។ ដ្បិត នាងក្រមុំបានចាប់ចិត្តស្រឡាញ់បងប្រុសបង្កើតរបស់នាង។ ក្ដីស្នេហារវាងបងប្អូនបង្កើតនេះមិនអាចទៅរួចឡើយ ប្រសិនបើម្ដាយឪពុករបស់ពួកគេដឹង ម៉្លោះហើយ អ្នកទាំងពីរក៏សម្រេចចិត្តពង្រត់គ្នាចេញពីផ្ទះ។ មុនមាន់រងាវ ពួកគេទាំងពីរបានពង្រត់គ្នាដោយជិះសេះសមួយ តែពេលសេះរត់នោះមានសត្វអន្ទង់ជាច្រើនតាមរុលពីក្រោយជើងសេះ រហូតធ្វើឱ្យបាក់ដីជាគំហុកៗ គ្រានោះសេះពិបាករត់ពេកដោយសារដឹកមនុស្សធ្ងន់ ខាងប្រុសក៏សម្រេចច្រានខាងស្រីទម្លាក់ ហើយបានស្លាប់នៅទីនោះ ក៏កើតជាព្រៃកដីកនេះទៅ។ ក្រោយមក គេក៏ហៅទីនោះថា "រលំស្រីស។ អ្នកស្រុកខ្លះទៀតនិទានរឿងស្រដៀងគ្នានេះដែរ តែខុសត្រង់ថា តួអង្គស្រីជាម្ដាយមីងរបស់ខាងប្រុស ស្រឡាញ់គ្នាតែត្រូវគេបំបែក ព្រោះខ្លាចបាប ក្រោយមកក៏ពង្រត់គ្នាដោយជិះសេះស ពេលនោះដោយសារបាបកម្មក៏ធរណីស្រូបស្លាប់បាត់ក្លាយជា "រលំ" ក៏ហៅទីនេះថា "រលំស្រីស។

រឿងព្រេងទាំងពីរខាងលើនេះ ផ្ដល់ពន្លឺជាច្រើនសម្រាប់យើងសាកល្បងពិចារណាអំពីឈ្មោះរបស់ព្រៃកដីកបុរាណនេះ ប៉ុន្តែយើងក៏មិនអាចយកមកយោងទាំងស្រុងបានឡើយ។ យើងស្នើថា ការហៅឈ្មោះព្រៃកដីកនេះថា "រលំស្រីស" ដូច្នេះ ទំនងមកពីមនុស្សជំនាន់មុនហៅសំដៅដល់ដីដែលបាក់ច្រាំង ឬទំនប់ដែលនៅសងខាងព្រៃកដីកបុរាណថា "រលំ" ហើយពាក្យ "ស្រីស" ខាងចុងអាចគេសំដៅដល់រូបទេពស្រីណាមួយដែលគេឃើញនៅប្រាសាទគ្រឹះប្រាង្គស្ថិតនៅជាប់មាត់ព្រៃកដីក។ ដ្បិត តាមប្រភពពីអ្នកស្រុកបានរៀបរាប់ថា ពីមុនមកនៅប្រាសាទគ្រឹះប្រាង្គគេធ្លាប់ឃើញរូបចម្លាក់ទេពស្រីមួយអង្គធ្វើអំពីថ្មភក់ ហើយបើនៅកណ្ដាលព្រៃកដីកចាស់ៗនិទានថាមានកីតម្បាញមួយធ្វើអំពីថ្ម។ យើងពុំដឹងថាកីតម្បាញធ្វើអំពីថ្មដែលគាត់រៀបរាប់នោះជាអ្វីឱ្យប្រាកដឡើយ ប៉ុន្តែការហៅឈ្មោះ "ស្រីស" សំដៅដល់រូបទេពស្រីដែលយើងគិតអាចសមហេតុផល ដ្បិតនៅក្នុងសង្គមខ្មែរគេនិយមហៅទេពស្រីនៃព្រហ្មញ្ញសាសនាថា "ស្រីខ្មៅ" ដែលសំដៅដល់ព្រះនាងទុគ៌ា (មហេសីរបស់ព្រះឥសូរ) ដូច្នោះ "ស្រីស" ក៏អាចចេញពីរូបទេពស្រីណាមួយដូច

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

គ្នា។ ម្យ៉ាងវិញទៀត ការសន្និដ្ឋានយ៉ាងស្ដួចស្ដើងមួយទៀតគឺ គេអាចហៅសំដៅដល់តួអង្គស្រីក្នុងរឿងព្រេង។

ដោយឡែក ប្រាសាទរលំ គឺជាប្រាសាទមួយដែលស្ថិតនៅក្នុងតំបន់ប្រាសាទកោះកេរ ក្នុងស្រុកគូលែន ខេត្តព្រះវិហារ។ ប្រាសាទនេះ មានទីតាំងស្ថិតនៅភាគពាយព្យប្រាសាទធំ ដែលសាងឡើងអំពីថ្មបាយក្រៀមពាក់កណ្ដាលនិងឥដ្ឋឥដ្ឋពាក់កណ្ដាល និងមានកំពែងព័ទ្ធជុំវិញធ្វើអំពីថ្មបាយក្រៀម[៧] ហើយទំនងសាងនៅស.វ.ទី១០ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ ដំណាលគ្នាជាមួយប្រាសាទដទៃទៀតនៅក្នុងតំបន់កោះកេរ (រូបលេខ១-២)។ លោក ហួន យ៉ាវ ធ្លាប់បានសាកសួរអ្នកស្រុកដែលរស់នៅតំបន់កោះកេរអំពីឈ្មោះប្រាសាទនេះដែរ តែអ្នកស្រុកបានឆ្លើយថា ការហៅដូច្នេះទំនងមកពីប្រាសាទនេះបានបាក់រលំ។ ប្រសិនបើយើងមើលតែតួប៉មកណ្ដាលរបស់ប្រាសាទយើងឃើញថា ប្រាសាទនេះមានឥដ្ឋធ្លាក់ជ្រុះមកក្រោមតិចតួចប៉ុណ្ណោះ ដូច្នេះហើយវាមិនអាចឆ្លើយតបស្របគ្នាជាមួយនិយមន័យ "រលំ" ដែលខ្មែរយើងប្រើប្រាស់សព្វថ្ងៃនេះបានទេ ដ្បិតទាល់តែដួលដេកទាំងស្រុង ទើបគេហៅថា "រលំ"។ យើងស្នើថា ការហៅប្រាសាទនេះថា "រលំ" ទំនងមកពីទីតាំងប្រាសាទនេះស្ថិតនៅក្បែរទំនប់ទឹក ដ្បិតភស្ដុតាងផ្នែកបុរាណវិទ្យាបង្ហាញឱ្យយើងឃើញថា ទីតាំងប្រាសាទស្ថិតនៅខាងចុងទំនប់ដីនៅតំបន់កោះកេរ (ពាយព្យប្រាសាទធំ)។ សូមបញ្ជាក់ថា នៅតំបន់កោះកេរមានទំនប់សំខាន់ៗចំនួនបី គឺទំនប់ខាងលិចប្រាសាទធំ ទំនប់ខាងជើងប្រាសាទធំ និងទំបន់ស្ថិតនៅផ្លូវបុរាណភ្ជាប់ពីក្រុងទៅកាន់ផ្លូវបុរាណដែលភ្ជាប់ពីតំបន់អង្គរទៅវត្តភូ។[៨] ទំនប់ទាំងអស់មានប្រឡាយទឹអមសងខាង កម្ពស់ ៧ឬ៨ម៉ែត្រ ហើយទំនប់នេះមានតួនាទីសំខាន់ពីរគឺ សម្រាប់ទប់ទឹក និងជាផ្លូវចូលមកកាន់ក្រុង។ ទំនប់នីមួយៗមានប្រវែង ៤-៥គ.ម. ហើយទំនងគេកសាងស្ពានឈើនៅកន្លែងទឹកឆ្លងកាត់[៩]។

ជារួមមក ស្ពាននាមបុរាណដ្ឋានទាំងពីរដែលមានឈ្មោះ "រលំ" ដូចបានរៀបរាប់ខាងលើនេះ ទំនងកើតឡើង និងមនុស្សជំនាន់មុនហៅសំដៅដល់ដីច្រាំងបាក់ ឬទំនប់ទឹក ដ្បិតន័យម្យ៉ាងទៀតរបស់ពាក្យ "រលំ" ដែលខ្មែរយើងប្រើតាំងពីបុរាណកាលមកមានន័យថា "ដីច្រាំងបាក់ និងទំនប់ទឹក" ពោល គឺស្ពាននាមទាំងពីរពុំមែនសំដៅលើការដួលរលំនោះឡើយ។

---

[៧] Parmentier 1939: 89; Boisselier 1966: 152.

[៨] ទឹម ធីតា ២០១៤: ២៣-៣១។

[៩] ដដែល

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

**កំ វណ្ណារ៉ា**

២០២០, "*កម្ពុជស្ថាននាមសម័យអង្គរ ស.វ.ទី៩-១៤*", ភ្នំពេញ

**ទឹម ជីតា**

២០១៤, "*ការរៀបចំប្រព័ន្ធគ្រប់គ្រងទឹកតំបន់កោះកេរ្តិ៍*", ភ្នំពេញ

**ឡុង សៀម**

១៩៩៧, "*ស្ថាននាមវិទ្យាខ្មែរ តាមឯកសារសិលាចារឹកប្រទេសកម្ពុជា ពីស.វ.ទី៦-១៤*", ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

**ពុទ្ធសាសនបណ្ឌិត**

១៩៦៧, "*វចនានុក្រមខ្មែរ*", ភ្នំពេញ

**Aymonier, Étienne**

1900, *"Le Cambodge"*, Tome 2, Paris

**Coedès, George**

1954, "*Inscription du Cambodge"*, Vol VI, Hanoi

**Parmentier, Henri**

1939, "*L'art Khmère classique, monuments du guardant nord-est*", EDD, Paris



រូបលេខ១៖ ប្រាសាទរលំ នៅតំបន់កោះកេរ (ប្រភព៖ ហួន យ៉ាវ)





រូបលេខ២-៣៖ ជញ្ជាំង និងចម្លាក់រូបទេពលើបំណែកផ្តែរទ្វារប្រាសាទរលំ នៅតំបន់កោះកេរ (ប្រភព៖ ហួន យ៉ាវ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី